# បណ្តុះបណ្តាលឲ្យក្លាយជាអ្នកដឹកនាំល្អ

កុមារជាង៤,០០០នាក់នៅក្នុងសហគមន៍គោលដៅបានរងគ្រោះដោយសារមេរោគអេដស៍ និងជម្ងឺ អេដស៍និងរងគ្រោះដោយសារប្រការផ្សេងទៀត និងមានកុមារ៣៩៣នាក់ផ្សេងទៀតកំពុងរស់នៅជាមួយមេរោគអេដស៍បាននិងកំពុងទទួលសេវាថែទាំ និងគាំទ្រពីអង្គការភីស៊ី។



ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាចាំបាច់របស់កុមារទាំងនេះ អង្គការភីស៊ីបានជ្រើសរើសកុមារចំនួន១៥២នាក់នៅក្នុងចំណោមកុមារដែលបានរៀបរាប់ខាងលើនៅក្នុងអង្គការទាំងមូលធ្វើកិច្ចសហការជាមួយប្រធានក្រុមជួយក្រុមដើម្បីជួយសម្របសម្រួលការងារជួយដល់កុមារ ។

តាមផែនការយុទ្ធសាស្រ្តចតុកោណក្នុងចំនុចទី៤របស់រាជរដ្ឋាភិបាល បានលើកឡើងពីការកសាងសមត្ថភាពនិងការអភិវឌ្ឍន៍ធនធានមនុស្ស ។ ដើម្បីឆ្លើយតបទៅនឹងផែនការយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល និងអនុវត្តតាមផែនការយុទ្ធសាស្រ្តរបស់ខ្លួន អង្គការភីស៊ីមានផែនការបណ្តុះបណ្តាលបុគ្គលិកនិងអ្នកស្មគ្រ័ចិត្តជារៀងរាល់ឆ្នាំឲ្យមានសមត្ថភាពគ្រប់គ្រាន់ដើម្បីរួមចំណែកឆ្លើយតបទៅនឹងតម្រូវការជាចាំបាច់របស់សហគមន៍។

នៅថ្ងៃទី២៣ដល់២៤ ខែឧសភា ឆ្នាំ២០១៣កន្លងទៅនេះ អង្គការភីស៊ីសាខាស្រុកប្រតិបត្តិបាទី បានបើកវគ្គបណ្តុះបណ្តាលនេះដល់កុមារជាប្រធានក្រុមគាំទ្រកុមារបានប្រព្រឹត្តក្រោមការសម្របសម្រួលរបស់លោកហែមគឹមអេងអ្នកសម្របសម្រួលប្រចាំស្រុកប្រតិបត្តិបាទី។

ប្រធានបទដែលបានលើមកពិភាក្សាមានចំនួន៤សំខាន់ៗគឺៈ

១-សុខភាពមាតា និងកុមារ

២-ចំណេះដឹងពីជម្ងឺរបេង

៣-ចំណេះដឹងពីជម្ងឺអេដស៍

៤-សិទ្ធិកុមារ និងបំណិនជីវិត

សមាជិកដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ ជាប្រធានក្រុមគាំទ្រកុមារចំនួន១៧នាក់/ស្រី០៨នាក់។ នៅក្នុងចំណោម១៧នាក់ដែលលបានចូលរួមវគ្គនេះ មានកុមារជាអ្នកផ្ទុកមេរោគអេដស៍ចំនួន៣នាក់/ស្រី១នាក់ និង១៤នាក់ផ្សេងទៀតជាកុមារកំព្រា កុមារងាយរងគ្រោះដោយសារមេរោគអេដស៍និងកុមារងាយរងគ្រោះដោយសារប្រការផ្សេងៗ។

តាមរយៈការបណ្តុះបណ្តាលនេះ កុមារទាំង១៧នាក់បានទទួលចំណេះដឹងពីប្រធានបទខាងលើបន្ថែមទៀតលើចំណេះដឹងផ្សេងទៀតដែលមានពីមុនមក។ ពួកគេមានការប្តេជ្ញាចិត្តយ៉ាងមុតមាំជួយដល់ក្រុមកុមារនិងសហគមន៍របស់ពួកគេឲ្យមានចំណេះដឹងពីសុខភាពអនាម័យ និងទទួលបាននូវសេវាសុខភាព និងសេវាផ្សេងៗដែលសហគមន៍ត្រូវការ ពួកគេសង្ឃឹមថា អំណឺះពីនេះទៅ សហគមន៍របស់ពួកគេនឹងកាត់បន្ថយបាននូវបញ្ហាដូចដែលមានសព្វថ្ងៃនេះជាមិនខាន។

# កម្មវិធីសប្បាយៗ

# បង្កើនការស្រឡាញ់និងសាមគ្គីភាព

នៅថ្ងៃទី ២២ ក្នុងខែឧសភា ឆ្នាំ២០១៣នេះកម្មវិធីសប្បាយៗមួយនៅក្នុងចំណោមកម្មវិធីសប្បាយជាច្រើន បានរៀបចំឡើងនៅក្នុងសហគមន៍របស់ខ្លួននៅភូមិធ្នង់ ឃុំឫស្សីស្រុកខាងកើត ស្រុកកំពង់ត្រាច ខេត្តកំពត។ កម្មវិធីនេះមានសមាជិកចូលរួមចំណួន៩៩នាក់ជាកុមារងាយរងគ្រោះនិងកុមារកំព្រាដោយសារមេរោគអេដស៍។



ជាឪកាសល្អសម្រាប់កម្មវិធី ក៏ដូចជាការចូលរួមនិងគាំទ្រលើកទឹកដល់កុមារនៅក្នុងកម្មវិធីនេះ លោកស្រី តេង ឫទ្ធីដា អនុប្រធានកម្មវិធីអដស៍ខេត្ត និងជាសមាជិកអចិន្ត្រៃយ៍គណៈកម្មការអេដស៍ខេត្តកំពតនិងអាជ្ញាធរមូលដ្ឋាននៅទីនោះក៏បានចូលរួមក្នុងកម្មវិធីនេះផងដែរ។ប្រធានបទនៅក្នុងកម្មវិធីសប្បាយៗនេះបានលើកឡើងចំនួនពីរសំខាន់គឺ៖ ទី១-សិទ្ធិកុមារ និងទី២-ការរើសអើង។

នៅក្នុងក្រុមធំលោកវេជ្ជបណ្ឌិត ប៉ែន សារី អ្នកសម្របសម្រួលអង្គការភីស៊ីប្រចាំស្រុកប្រតិបត្តិកំពង់ត្រាចបានលើកឡើងជាសំនួរខ្លះៗទាក់ទងនឹងសិទ្ធិរបស់កុមារសួរដល់ក្រុមធំថា៖ តើសិទ្ធិរបស់កុមារមានប៉ុន្មាន? និងអ្វីខ្លះ? និងមូលហេតុដែលនាំឲ្យមានការរើសអើងចំពោះកុមារផងគ្នានៅក្នុងសហគមន៍ជាពិសេសកុមាររងគ្រោះដោយសារមេរោគអេដស៍។ កុមារនៅក្នុងក្រុមស្ទើរតែទាំងអស់មានការយល់ដឹងច្រើននិងបានចូលរួមឆ្លើយនូវសំនួរបានយ៉ាងល្អនិងផុលផុស។



លោកស្រី តេង ឫទ្ធីដា ក៏បានលើកសរសើរពីការចូលរួមរបស់កុមារនាពេលធ្វើសកម្មភាពក្នុងកម្មវិធីនេះ និងធ្វើការបកស្រាយនូវចម្ងល់របស់កុមារដែលមិនទាន់បានច្បាស់។

បន្ទាប់មកកម្មវិធីបានបែងចែកកុមារជាបីក្រុមតូចៗ ឲ្យកុមារលែងល្បែងឋាមពល។ ល្បែងទាំងនោះពាក់ព័ន្ធនឹង ការងារជាក្រុម ការងារជាបណ្តាញ វិធីផ្ញើសារនិងទទួលសារជាដើម។

ក្រុមទាំងបីក្រុមនេះ មានសមាសភាពចំរុះ មានទាំងកុមារផ្ទុកមេរោគអេដស៍ កុមាររងគ្រោះដោយសារមេរោគអេដស៍ និងកុមារងាយរងគ្រោះដោយសារប្រការផ្សេងទៀតបានចូលរួមយ៉ាងសកម្មមិនមានការច្រានចោលនូវសំណើឬសំណូមពរពីចូលរួមរបស់កុមារដែលជាសមាជិកណាមួយឡើយ។ បរិយាកាសដ៏ល្អនេះបានបង្កឲ្យកុមារដែលកំពុងប្រឈមនឹងបញ្ហាផ្នែកសុខភាព ផ្នែកអារម្មណ៍និងបញ្ហាផ្សេងទៀតមានទឹកចិត្តកាន់តែខ្លាំងឡើង និងបង្កលក្ខណះឲ្យកុមារមានភាពស្និទ្ធស្នាលសុខុដមរមនាជាមួយគ្នា ដោយមិនគិតពីស្ថានភាពឡើយ។ សកម្មភាពនេះបានប្រព្រឹត្តទៅអស់រយះពេល១ម៉ោងប្រកបដោយភាពរីករាយនិងស្និទ្ធស្នាលជាទីបំផុត។

# ករណីសិក្សា

## ជួយមនុស្សម្នាក់ឲ្យមានសុខភាពល្អ គឺបានជួយសហគមន៍ឲ្យមានការរីកចម្រើន

មណ្ឌលសុខភាពដូង ជាមណ្ឌលសុខភាពមួយក្នុងចំណោមមណ្ឌលសុខភាពទាំង១៣នៃស្រុកប្រតិបត្តិបាទី ដែលកំពុងសហការអនុវត្តគម្រោងពង្រឹងប្រព័ន្ធសេវាសុខភាពមូលដ្ឋានជាមួយអង្គការភីស៊ី។ មណ្ឌលសុខភាពដូង បានគ្របដណ្តប់លើភូមិចំនួន២០ និងឃុំចំនួន៤គឺ ឃុំ ចំបី ឃុំដូង ឃុំត្នោត និងឃុំពារាម ដែលមានអ្នកស្មគ្រចិត្តសុខភាពភូមិចំនួន៤០នាក់។

លោក ជា សែម អាយុ ៥៧ឆ្នាំ រស់នៅក្នុងភូមិជម្រៅ ឃុំពារាម ជាអ្នកស្ម័គ្រចិត្តម្នាក់ក្នុងចំណោម អ្នកចិត្ត៤០នាក់ បានមានប្រសាសន៍ថា៖ ខ្ញុំបាទបានស្ម័គ្រចិត្តធ្វើជាភ្នាក់ងារសុខភាពភូមិអស់រយៈពេល១៥ឆ្នាំហើយ កន្លងមកខ្ញុំបានដើរផ្សព្វផ្សាយ ចាក់ថ្នាំវាក់សាំងបង្ការ យុទ្ធនាការផ្តល់ជីវជាតិអា និង ស្រាវជ្រាវរកអ្នកជម្ងឺរបេង។



លោកបន្តទៀតថា៖ ក្នុងនាមជាអ្នកស្ម័គ្រចិត្តឲ្យមណ្ឌលសុខភាព លោកបានធ្វើជាអ្នកស្ម័គ្រ ចិត្តឲ្យអង្គការមួយចំនួនទៀត តែខ្ញុំមិនសូវបានដឹងពីតួនាទីនិងភារកិច្ចរបស់អ្នកស្មគ្រចិត្តទេ ធ្វើការ ងារតាមតែការណែនាំរបស់អង្គការប៉ុណ្ណោះ។

នៅពេលដែលអង្គការភីស៊ីបានគាំទ្រនិងសហការជាមួយគណកម្មការគ្រប់គ្រងមណ្ឌលសុខភាពដូងនាឆ្នាំ ២០១០មក រូបខ្ញុំត្រូវបានអញ្ជើញចូលរួមបណ្តុះបណ្តាលជាច្រើនដូចជា៖ ការបណ្តុះ បណ្តាលពីតួនាទីនិងភារកិច្ចជាអ្នកស្ម័គ្រចិត្ត ពីសេវាសុខភាពសាធារណៈ ជម្ងឺរបេង សិទ្ធិអ្នកប្រើ ប្រាស់សេវា។ ក្រោយពីបានយល់ដឹងបន្ថែមពីតួនាទីនិងភារកិច្ច រូបខ្ញុំបាទបានបំពេញតួនាទីដូចជា៖ ការអប់រំសុខភាពដល់សហគមន៍ ចូលរួមប្រជុំប្រចាំត្រីមាសរបស់អ្នកស្ម័គ្រចិត្ត និងបញ្ជូនអ្នកជម្ងឺទៅទទួលសេវាសុខភាពនៅមណ្ឌលសុខភាព។

លោកបានបន្តទៀតថា៖ ខ្ញុំប្តេជ្ញា បន្តធ្វើជាអ្នកស្មគ្រចិត្តជួយគាំទ្រដល់មណ្ឌលសុខភាពឲ្យកាន់តែខ្លាំងក្លាជាងនេះទៀត ដើម្បីគាំទ្រនិងអប់រំដល់ប្រជាជននៅក្នុងភូមិឲ្យបានយល់ពីសារសំខាន់របស់សុខភាព និងជួយពង្រឹងប្រព័ន្ធបញ្ជូននិងបញ្ជូនអ្នកជម្ងឺទៅទទួលសេវាឲ្យបានទាន់ពេលវេលា មានន័យថា៖ ជួយមនុស្សម្នាក់ឲ្យមានសុខភាពល្អ គឺបានជួយសហគមន៍ឱ្យមានការរីកចម្រើន។

## ករណីសិក្សា

# គ្រួសារយើងខ្ញុំមានសង្ឃឹមសារជាថ្មី

ផល ផាណែត មានអាយុ១០ឆ្នាំ រៀនថ្នាក់ទី៤ នៅសាលាបឋមសិក្សាអង្គរុន និងជាកូនស្រីទី២របស់អ្នកស្រី រស់ ផានី ក្រោមការគ្រប់គ្រងរបស់លោកតា រស់ ឆិល ជាបុរសពោះម៉ាយមានវ័យ៧៤ឆ្នាំនៅភូមិគោដូល ឃុំត្រពាំងក្រសាំង ស្រុកបាទី ខេត្តតាកែវ។ ផាណែត មានម្តាយជាស្ត្រីមេម៉ាយហើយគនិងថ្លង់ទៀតផង។

តាមប្រសាសន៏របស់លោកតា រស់ ឆិលជាជីតារបស់ផាណែតថា៖ ម្តាយរបស់ ផាណែត មិនដែលមានសេចក្តីសុខទេ នៅក្នុងជីវិតជាមនុស្សគនិងថ្លង់។ មានបុរសចំនួន២នាក់បានមកបោកប្រាស់នាង បុរសទីមួយយកនាងបានកូនប្រុសមួយហើយបោះបង់ចោល ឯបុរសទី២ក៏ដូចគ្នាដែរយកបានកូនស្រីមួយក៏បោះបង់ចោលទៀត។



លោកតាបានបន្តទៀតថា៖ នៅថ្ងៃទី ២៧ ខែមិនាឆ្នាំ ២០១៣វេលាម៉ោង៣រសៀលកន្លងទៅនេះមិនដឹងជាចៃដន្យអាក្រក់អីកូនខ្ទមដ៏តូចមួយនិងទ្រព្យសម្បត្តិបន្តិចបន្តួចជាកេរ្តិ៍ចុងក្រោយសម្រាប់ជីវិតខ្ញុំ និងជាជម្រកសម្រាប់ចៅនិងកូន អគ្គិភ័យបានត្របាក់ឆាបឆេះអស់សល់តែគ្រោងឆ្អឹងនិងរនូតខ្លះតែប៉ុណ្ណោះ។



ក្រោយពីខ្ទមកំសត់ត្រូវបានភ្លើងឆាបឆេះអស់ ខ្ញុំគ្មានជំរកឯណាដើម្បីជ្រកទៀតទេ យើងបានប្រមូលកំណាត់ឈើដែលសល់ភ្លើងឆាបឆេះនោះយកធ្វើជាកូនគ្រែ និងបោះតង់ស្នាក់នៅជាបណ្តោះអាសន្ន ក្រោមកិច្ចសហការល្អជាមួយរង្វង់អំណាចមូលដ្ឋាន កាកបាទក្រហមប្រចាំស្រុក និងសប្បុរសជននានា អង្គការភីស៊ីបានចូលរួមចំណែកជួយតម្រូវការជាមូលដ្ឋានដូចជា មុង ភួយ កន្ទេល និងសម្ភារះមួយចំនួនផ្សេងទៀតដូចជាស្លឹកនិងឈើដើម្បីឲ្យលោកតាមានលទ្ធភាពសាងសង់កូនខ្ទមឡើងវិញដើម្បីជាជម្រកនិងលើកស្ទួយជីវភាពរស់នៅរបស់គ្រួសារក្រីក្ររងគ្រោះមហន្តរាយមួយនេះ។

តាមសម្តីរបស់កុមារី ផល ផាណែត ជាកុមារក្រោមការគាំទ្ររបស់អង្គការភីស៊ីថា នាងខ្ញុំមានចិត្តសប្បាយរីករាយជាអនេកដែលបានអង្គការនិងសប្បុរសជនបានជួយដល់គ្រសារនាងខ្ញុំនៅពេលដែលមានគ្រោះអាសន្ន ជាពិសេសអង្គការភីស៊ីបានជួយដល់គ្រួសារនាងខ្ញុំជាគ្រួសារក្រីក្រ និងបានគាំទ្រដល់នាងឲ្យខ្ញុំមានឪកាសបានបន្តការស្ថិក្សា នាងខ្ញុំប្តេជ្ញានឹងខិតខំរៀនសូត្រដើម្បីអនាគតមួយភ្លឺស្វាង។